# ខ្លឹមសារសង្ខេប
# ទស្សនៈរបស់គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ( UNHRC )
# បណ្ដឹងលេខ ៨៦៩/១៩៩៩

**១.ពាក្យគន្លឹះ៖** ការប្រព្រឹត្តមិនគម្បី ឬទារុណកម្ម, ទោសប្រហារជីវិត

**២. នីតិវិធី៖** អ្នកប្ដឹង ជាជនជាតិហ្វីលីពីន ត្រូវបានចោទពីបទប្លន់ សម្លាប់ និងត្រូវបានផ្ដន្ទាទោសប្រហារជីវិត។ គាត់ចោទថា គាត់ត្រូវបានឃាត់ខ្លួន និងបានអះអាងថា ត្រូវបានវាយដំលើពោះ មិនមានមេធាវីតំណាងជួយការពារទេ។ គាត់បន្ថែមថា ការដាក់ទោសប្រហារជីវិតនេះ ជាការខុសឆ្គង ពីព្រោះបទល្មើសដែលគាត់ប្រព្រឹត្ត មិនមានជនល្មើសបីរូប ដែលចូលក្នុងស្ថានទម្ងន់ទោសទេ។ ជាចុងក្រោយ សាក្សីដែលកំណត់អត្តសញ្ញាណជនល្មើស គឺជាមិត្តភ័ក្រជិតស្និទ្ធរបស់ជនរងគ្រោះ ដែលបានស្លាប់។ ជាមួយគ្នានេះដែរ ចៅក្រម មិនបានផ្ដល់តម្លៃលើការដោះសារ មិននៅកន្លែងកើតហេតុ (*alibi*) ឡើយ។

រដ្ឋភាគី បានឆ្លើយតបថា បទល្មើសរបស់ជនល្មើស បានប្រព្រឹត្តិលើមន្ត្រីប៉ូលីស។ ការចោទអំពីអំពើទារុណកម្ម ឬទង្វើមិនគម្បី មិនត្រូវបានលើកនៅមុខតុលាការកំពូល។ ប្រសិនបើត្រូវបានលើក ហើយមានភស្ដុតាងបង្ហាញ មានការប្រព្រឹត្តមិនគម្បីធ្ងន់ធ្ងរ សាលក្រមរបស់តុលាការជាន់ទាប នឹងត្រូវបានបដិសេធ។

## ៣. សំអាងហេតុ និងសេចក្ដីសម្រេច

**ក.** ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនល្មើស (អ្នកប្ដឹង) ដែលអះអាងថា មានភាពមិនត្រឹមត្រូវ គណៈកម្មាធិការបានអះអាងថា ការកំណត់អត្តសញ្ញាណក្នុងអំឡុងពេលស៊ើបអង្កេតដោយប៉ូលីស និងក្នុងអំឡុងពេលសវនាការ វាមិនមានអ្វីពាក់ព័ន្ធ ឬការបំពានអ្វីនឹងមាត្រា១៤នៃកតិកាសញ្ញា។

**ខ.** ពាក់ព័ន្ធនឹងការចោទថាមានការប្រព្រឹត្តមិនគម្បី គណៈកម្មាធិការ ពិចារណាឃើញថា បញ្ហានេះត្រូវបានដាក់ជូនទៅមុខតុលាការជាតិ ហើយតុលាការ បានពិចារណា និងបដិសេធ។ គណៈកម្មាធិការ មិនឃើញមានភស្ដុតាងថា សេចក្ដីសម្រេចរបស់តុលាការជាតិពាក់ព័ន្ធនឹងបញ្ហានេះ មានលក្ខណៈបំពារបំពានដែលជាការបដិសេធនូវយុត្តិធម៌នោះទេ។

អាស្រ័យហេតុនេះ គណៈកម្មាធិការ មិនបានរកឃើញថា មានការរំលោភមាត្រាណាមួយនៃកតិកាសញ្ញា ដូចដែលចោទដោយអ្នកប្ដឹងឡើយ។

**៤. កំណត់សំគាល់ (ខ្លឹមសារល្អ សម្រាប់ដកស្រង់)**

*គណៈកម្មាធិការ សូមរំលឹកនូវយុត្តិសាស្ត្ររបស់ខ្លួនថា ជាទូទៅ វាសម្រាប់ តុលាការរបស់រដ្ឋភាគី និងមិនមែនសម្រាប់គណៈកម្មាធិការទេ ក្នុងការវាយតម្លៃអង្គហេតុ និង ភស្តុតាងក្នុងករណីជាក់លាក់* (កថាខ័ណ្ឌទី៧.២)។

ទស្សនៈទាំងស្រុងសូមមើល៖ CCPR/C/70/D/869/1999, Communication No. 869, *Piandiong v. the Philippines*